**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី២៤)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១០ ៥០១ នាក់ នៃរោងចក្រ សហគ្រាស ទាំង៤៤ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៤៤ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ពុធ ៨រោច ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៤៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 29 |
| 1 | ក្រុមហ៊ុន ជីន ចាយ ហ៊ាន បើក ម៉ាយីង (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ផានថេសសា ហ្គាមេន (ខេមបូឌា) | ភ្នំពេញ |
| 3 | ក្រុមហ៊ុន មេទីណាហ្វិតវែរ | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ខល័រ ជាឡេតតេ ហ្គាមិន អិកសេសសឺរីឯ.ក | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ថុង ឆាវ អេនធើប្រាយ (ខេមបូឌា) អិលធីឌី | ភ្នំពេញ |
| 6 | ក្រុមហ៊ុន យីង ហ្វេសិន ហ្គាមេន | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ហ៊ុង ស៊ីង ហ្គាមិន (ខេមបូឌា) ឯ.ក | កណ្តាល |
| 8 | ក្រុមហ៊ុន ណាហ្គាភីស ខបភើរេសិន លីមីធីត_1 | កណ្តាល |
| 9 | ក្រុមហ៊ុន ហ៊ីលថប ឡាក់ហ្គេដ (ខេមបូឌា) ឯ.ក | កណ្តាល |
| 10 | ក្រុមហ៊ុន អេច អ ហ្វ្រេន ហ្គាមិន (ខេមបូឌា) | កណ្តាល |
| 11 | ក្រុមហ៊ុន ជីនវីន អ៊ីនដាសស្ទ្រី ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 12 | ក្រុមហ៊ុន បូវយើ ហ្គាមេន ព្រីនធីង(ខេមបូឌា)ខមភេនី លីមីធីត | កណ្តាល |
| 13 | ក្រុមហ៊ុន សាប្រីណា (ខេមបូឌា) ហ្គាមិន ម៉ែនញ៉ូហ្វាក់ធីរីន ខប | កំពង់ស្ពឺ |
| 14 | ក្រុមហ៊ុន ឈីហាង ញូ (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 15 | ក្រុមហ៊ុន វីនគ្រោន (ខេមបូឌា) អិនដាសស្ទ្រៀល ឯ ក | កំពង់ស្ពឺ |
| 16 | ក្រុមហ៊ុន ហ៊ីរ៉ូតា (ខេមបូឌា) ហ្គាមិន | កំពង់ស្ពឺ |
| 17 | ក្រុមហ៊ុន ញូខាំមើ ឡាក់ហ្គេដ អេនប៉ែក (ខេមបូឌា) មេនូហ្វេកធីរីង ឯ.ក | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន ប្រាយ ហ្វ្លាស់ស៊ីង ឯ.ក | តាកែវ |
| 19 | ក្រុមហ៊ុន ហាធ័រអ៊ិនធើណេសិនណល(ខេមបូឌា)ឯ.ក | តាកែវ |

| ល.រ | ឈ្មោះពេទចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 20 | ក្រុមហ៊ុន អ៊ី-ចេង (ខេមបូឌា) ឧបភើរេសិន | តាកែវ |
| 21 | ក្រុមហ៊ុន តាកែវស៊ូ (ខេមបូឌា) ខូ.,អិលធីឌី | តាកែវ |
| 22 | ក្រុមហ៊ុន ស្កាយណាយ2 អ៊ិនធើណេសិនណល ខូអិលធីឌី | កំពង់ចាម |
| 23 | ក្រុមហ៊ុន ជាតាន់ អ៊ិនជាសស្ទ្រៀល ឯ ក ស្រុកព្រៃឈរ | កំពង់ចាម |
| 24 | ក្រុមហ៊ុន ខេមបូឌានស៊ីកនេតឈ័រ ថេកស្តាយ ឯ ក | ស្វាយរៀង |
| 25 | ក្រុមហ៊ុន យីងម៉េកឃើ(ខេមបូឌា)ហ្វូតវែរ | ស្វាយរៀង |
| 26 | ក្រុមហ៊ុន ហ៊ែលសា សៅអ៊ិសអេស៊ា ខូអិលធីឌី | ស្វាយរៀង |
| 27 | ក្រុមហ៊ុន ខេមបូឌាន យុនគុន ឯ.ក | ព្រះសីហនុ |
| 28 | ក្រុមហ៊ុន ស៊ីសុផុន ហុង សេង ស្ព័តវែរ ឯ.ក | បន្ទាយមានជ័យ |
| 29 | ក្រុមហ៊ុន ធី.ខេ ហ្គាមេន ស៊ីសុផុន | បន្ទាយមានជ័យ |
| ខ. វិស័យទេសចរណ៍ | | 15 |
| 30 | ក្រុមហ៊ុន អេមខេត (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 31 | ក្រុមហ៊ុន សិប្បករអង្គរ ភ្នំពេញ | ភ្នំពេញ |
| 32 | ក្រុមហ៊ុន ក្រែសសបភើ ធួរ (ខេមបូឌា ) | សៀមរាប |
| 33 | ក្រុមហ៊ុន សិប្បករអង្គរ | សៀមរាប |
| 34 | ភោជនីយដ្ឋានសុខៈរីវើ | សៀមរាប |
| 35 | ក្រុមហ៊ុន អង្គរ ប៉ាណូរ៉ាមីក ប៊ូទិក ឯ.ក | សៀមរាប |
| 36 | សណ្ឋាគារ អង្គរ ហូតែល គ្រុប(សណ្ឋាគារ អប្សរា ជាទ្បេស) | សៀមរាប |
| 37 | ក្រុមហ៊ុន កាទ្បាស ខម(ខេមបូឌា)ភីធីអ៊ីអិលធីឌី (សណ្ឋាគារ អង្គរ អេរ៉ា) | សៀមរាប |
| 38 | ក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស | សៀមរាប |
| 39 | ក្រុមហ៊ុន ដឹសឃ្សៃ24 | សៀមរាប |
| 40 | ក្រុមហ៊ុន ម៉ុនស៊ូន អេស៊ាន បីស្ត្រូ | សៀមរាប |
| 41 | ក្រុមហ៊ុន ខហ្វហ្វី ខនសិប (ខេមបូឌា) លីមីធីត (សាខាខេត្តសៀមរាប) | សៀមរាប |
| 42 | ក្រុមហ៊ុន ភូមិឧទ្បាន ហ្គាដិនវីលេច | សៀមរាប |
| 43 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( អង្គរធីខេត្រាវែល ធួរ) | សៀមរាប |
| 44 | ក្រុមហ៊ុន ហ៊្វូដ អេន បេវើរិច សឺលូសិន | សៀមរាប |